ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៥៦)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៩ ៥៤១នាក់ នៃរោងចក្រ សហគ្រាសទាំង៣៩ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីងនឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ៦០ ០០០រៀល (១៥ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២០ ០០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦០ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។ សូមបញ្ជាក់ថា សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ប្រាក់ឧបត្ថម្ភនឹងត្រូវបើកជា ២លើក ដោយលើកទី២ នឹងបើកនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីងនឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាសទាំង៣៩ នេះ មិនបានទទួលសារទូរសព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ ពុធ ៣រោច ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០២១

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

### ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១

### បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍ ចំនួន ៣៩ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 19 |
| 1 | ក្រុមហ៊ុន អិម ធី យេស៍ ហ្គាមេន (ខេមបូឌា) | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ផ្លេកថាម (ខេមបូឌា) អ៊ីភែរីល លីមីធីត | ភ្នំពេញ |
| 3 | ក្រុមហ៊ុន ហ្វ្រេត យូញៀន (ខេមបូឌា) ហ្គាមេន ខូ អិលធីឌី | ភ្នំពេញ |
| 4 | ក្រុមហ៊ុន អ៊ី អិម ប៊ី ដែលគូរី (ខេមបូឌា) | ភ្នំពេញ |
| 5 | ក្រុមហ៊ុន ហុង វ៉ា (កម្ពុជា) ហ្គាមិន ម៉ាញូហ្វាក់ធីរីង លីមីធីត | ភ្នំពេញ |
| 6 | ក្រុមហ៊ុន ដាយ នឹង ព្រីនធីង អឹមប្រយឌើរី ឯ.ក | ភ្នំពេញ |
| 7 | ក្រុមហ៊ុន ជា ជា ហ៊ី ហ្គាម៉ិន (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 8 | ក្រុមហ៊ុន ញូ ហ្វូខឹស អ៊ីភែរីល (ខេមបូឌា) ឯ ក | កណ្តាល |
| 9 | ក្រុមហ៊ុន ខេមបូ យូនីសូល អិលធីឌី | កណ្តាល |
| 10 | ក្រុមហ៊ុន ឌ្រីម ថយ អ៊ីនធើណេសិនណល ខូអិលធីឌី | កណ្តាល |
| 11 | ក្រុមហ៊ុន ជីនវីន អ៊ីនដាសស្ទ្រី ខេមបូឌា ខូអិលធីឌី | កណ្តាល |
| 12 | ក្រុមហ៊ុន អេស យ៉ន (ខេមបូឌា) អឹមភែរីល មេនូហ្វេកឆឺរីង | កំពង់ស្ពឺ |
| 13 | ក្រុមហ៊ុន ហ្សុងហ្វ័រយុនជីន (ខេមបូឌា) ហ្គាមេនខូអិល ធីឌី | កំពង់ស្ពឺ |
| 14 | ក្រុមហ៊ុន លីឌីង ស្តារ (ខេមបូឌា)ហ្គាម៉ិន ឯ.ក | តាកែវ |
| 15 | ក្រុមហ៊ុន ណាញ ស្តាយ ហ្គាម៉ិន ឯ.ក | តាកែវ |
| 16 | ក្រុមហ៊ុន ហ្វ្រេសហ្វូល(ខេបូឌា)ថេកស្តាយ ខូ.អិលធីឌី | តាកែវ |
| 17 | ក្រុមហ៊ុន ត្រីប៉ូស អ៊ិនធើណេសិនណល (ខេមបូឌា) ខូរ., អិលធីឌី | កំពង់ឆ្នាំង |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 18 | ក្រុមហ៊ុន ថបស៊ីលវើរ លីមីធីត (សាខាទី1) | ត្បូងឃ្មុំ |
| 19 | ក្រុមហ៊ុន អរិន មេនូហ្វេកឆឺរីង ( ខ្មែរ ) | ព្រៃវែង |
| ខ. វិស័យទេសចរណ៍ | | 20 |
| 20 | ក្រុមហ៊ុន ឌីថាមត្រាវែល ខេមបូឌា | ភ្នំពេញ |
| 21 | ក្រុមហ៊ុន ដារ៉ា អ៊ែរផត ហូថេល | ភ្នំពេញ |
| 22 | សណ្ឋាគារ ហ្គាឌិន ស៊ីធី ហូថេល | ភ្នំពេញ |
| 23 | សណ្ឋាគារ ភ្នំពេញ អេរ៉ា ហូថេល ឯ.ក | ភ្នំពេញ |
| 24 | ក្រុមហ៊ុន រ៉ាហ្វលមហាសណ្ឋាគារអង្គរ | សៀមរាប |
| 25 | ក្រុមហ៊ុន ហ្វ៊ូដ អេន បេវើរិច សឺលូសិន | សៀមរាប |
| 26 | សណ្ឋាគារម៉េម៉ររសៀមរាប | សៀមរាប |
| 27 | ក្រុមហ៊ុន ទន្លេសាបចៅផាយ៉ា( ភោជនីយដ្ឋានទន្លេចតុមុខ) | សៀមរាប |
| 28 | ក្រុមហ៊ុន ទន្លេសាបចៅផាយ៉ា( ភោជនីយដ្ឋានទន្លមេគង្គ) | សៀមរាប |
| 29 | ក្រុមហ៊ុន ទន្លេសាបចៅផាយ៉ា( ភោជនីយដ្ឋានទន្លេសាប) | សៀមរាប |
| 30 | សណ្ឋាគារ អង្គរមិរ៉ាខល រីហ្សត និង ស្ប៉ា | សៀមរាប |
| 31 | ក្រុមហ៊ុន អេច ឌី រ៉ក កាហ្វេ & សប | សៀមរាប |
| 32 | ក្រុមហ៊ុន ម៉េម៉ររអង្គរ (ខេមបូឌា) | សៀមរាប |
| 33 | សណ្ឋាគារ លីនាយាអង្គរ រីសត និងស្ប៉ា | សៀមរាប |
| 34 | សណ្ឋាគារសុខាល័យអង្គរ រីហ្សត និងស្ប៉ា | សៀមរាប |
| 35 | ក្រុមហ៊ុន អឹបៅអេស៊ា | សៀមរាប |
| 36 | ក្រុមហ៊ុន ត្រេហ្ស៊ឺ អូអេស៊ីស | សៀមរាប |
| 37 | ក្រុមហ៊ុន អង្គរ សេនជូរី គ្រុប ភីធីអ៊ី អែលធីឌី | សៀមរាប |
| 38 | ក្រុមហ៊ុន អេប៉ិច ខេមបូឌា ត្រាវែល សែរវីស | សៀមរាប |
| 39 | សណ្ឋាគារ ឋានសួគ៌សុខា | កំពត |